**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ២១៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការដឹកនាំអនុវត្តផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តមណ្ឌលគិរី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ១៦៨ អនក្រ.បក ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍
- បានឃើញលិខិតលេខ ៤២៨ សជណ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

ត្រូវបានបង្កើតគណៈកម្មាធិការដឹកនាំអនុវត្តផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តមណ្ឌលគិរី ដែលសរសេរជាអក្សរកាត់ថា **គ.ដ.ផ.ម.** ដើម្បីដឹកនាំអនុវត្តផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តមណ្ឌលគិរី (២០២១-២០៣៥) ដែលបានទទួលការអនុម័តពីរាជរដ្ឋាភិបាល កាលពីថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១។

## ជំពូកទី២

## សមាសភាពនៃ គ.ដ.ផ.ម.

**មាត្រា២.-**

សមាសភាពនៃ **គ.ដ.ផ.ម.** មានដូចខាងក្រោម÷

| | | |
|---|---|---|
| ១- | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | ប្រធាន |
| ២- | រដ្ឋមន្ត្រីក្រសួងបរិស្ថាន | អនុប្រធាន |
| ៣- | រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៤- | រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | អនុប្រធាន |
| ៥- | រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | អនុប្រធាន |
| ៦- | អភិបាលនៃគណៈអភិបាលខេត្តមណ្ឌលគិរី | អនុប្រធាន |
| ៧- | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ១រូប | សមាជិក |
| ៨- | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ១រូប | សមាជិក |
| ៩- | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប | សមាជិក |
| ១០- | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ ១រូប | សមាជិក |
| ១១- | រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន ១រូប | សមាជិក |
| ១២- | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យានិងនវានុវត្តន៍ ១ រូប | សមាជិក |
| ១៣- | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ ១រូប | សមាជិក |
| ១៤- | រដ្ឋលេខាធិការក្រសួងអប់រំ យុវជននិងកីឡា ១រូប | សមាជិក |
| ១៥- | រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម ១រូប | សមាជិក |
| ១៦- | រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ១រូប | សមាជិក |
| ១៧- | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ១រូប | សមាជិក |
| ១៨- | រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ១រូប | សមាជិក |
| ១៩- | រដ្ឋលេខាធិការក្រសួងសុខាភិបាល ១រូប | សមាជិក |

២០- រដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល ១រូប — សមាជិក

២១- រដ្ឋលេខាធិការក្រសួងទេសចរណ៍ ១រូប — សមាជិកប្រចាំការ

២២- អគ្គស្នងការនគរបាលជាតិ — សមាជិក

២៣- មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស — សមាជិក

២៤- អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា — សមាជិក

២៥- អគ្គនាយកអគ្គិសនីកម្ពុជា — សមាជិក។

សមាសភាពជាក់ស្តែងនៃ **គ.ជ.ផ.ម.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៣

## តួនាទីនិងភារកិច្ចរបស់ គ.ជ.ផ.ម.

**មាត្រា៣.-**

**គ.ជ.ផ.ម.** ជាសេនាធិការជូនរាជរដ្ឋាភិបាលដែលមានតួនាទីនិងភារកិច្ចដូចខាងក្រោម÷

- ដឹកនាំអនុវត្តផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តមណ្ឌលគិរី (២០២១-២០៣៥)
- សម្របសម្រួល និងតាមដានការអនុវត្តផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តមណ្ឌលគិរី (២០២១-២០៣៥)
- អនុវត្តផែនការសកម្មភាព និងគម្រោងអាទិភាព ដូចបានកំណត់ក្នុងផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តមណ្ឌលគិរី (២០២១-២០៣៥)
- រៀបចំលិខិតបទដ្ឋានគតិយុត្តចាំបាច់នានា ដើម្បីដឹកនាំអនុវត្តផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តមណ្ឌលគិរី (២០២១-២០៣៥) ឱ្យមានប្រសិទ្ធភាព
- ពិនិត្យ អនុម័ត និងគ្រប់គ្រងផែនការសកម្មភាពរបស់ **គ.ជ.ផ.ម.**
- ធ្វើរបាយការណ៍វាយតម្លៃតាមដំណាក់កាលអំពីលទ្ធផលនៃការអនុវត្តផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តមណ្ឌលគិរី (២០២១-២០៣៥)
- ពិនិត្យវាយតម្លៃ និងអនុម័តគម្រោងនានាដែលពាក់ព័ន្ធការអភិវឌ្ឍន៍វិស័យទេសចរណ៍ក្នុងខេត្តមណ្ឌលគិរី
- ពិនិត្យ និងតាមដានរាល់ប្រតិបត្តិការគម្រោងអភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តមណ្ឌលគិរី
- ដឹកនាំរៀបចំព្រឹត្តិការណ៍ និងសកម្មភាពនានាក្នុងការជំរុញការអភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តមណ្ឌលគិរី
- ផ្តល់ការបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពទៅដល់គ្រប់ភាគីពាក់ព័ន្ធដើម្បីជំរុញការអភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តមណ្ឌលគិរី
- កៀរគរធនធានហិរញ្ញវត្ថុពីប្រភពស្របច្បាប់នានា ដើម្បីទ្រទ្រង់ការអនុវត្តផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តមណ្ឌលគិរី (២០២១-២០៣៥)
- ធ្វើការសហការជាមួយក្រសួង ស្ថាប័ន អង្គការជាតិ និងអន្តរជាតិ ផ្នែកឯកជន និងភាគីពាក់ព័ន្ធទាំងអស់ ដើម្បីជំរុញការអនុវត្តផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តមណ្ឌលគិរី (២០២១-២០៣៥) ឱ្យមានប្រសិទ្ធភាព
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនដោយរាជរដ្ឋាភិបាល។

## ជំពូកទី៤

## ការប្រព្រឹត្តទៅនៃ គ.ជ.ផ.ម.

**មាត្រា៤.-**

**គ.ជ.ផ.ម.** បើកកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន ឬមានធុរៈ អនុប្រធានត្រូវដឹកនាំកិច្ចប្រជុំ **គ.ជ.ផ.ម.** តាមការប្រគល់សិទ្ធិរបស់ប្រធាន។

**មាត្រា៥.-**

ប្រធាន **គ.ជ.ផ.ម.** អាចអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ មន្ត្រីជំនាញ អ្នកឯកទេសឬផ្នែកឯកជន ឱ្យចូលរួមប្រជុំពិគ្រោះយោបល់និងសិក្សាស្រាវជ្រាវលើរាល់ការងារទាំងឡាយដែលទាក់ទងនឹង **គ.ជ.ផ.ម.**។

**មាត្រា៦.-**

**គ.ជ.ផ.ម.** មានសិទ្ធិបង្កើតអនុគណៈកម្មការនិងក្រុមការងារបច្ចេកទេសតាមការចាំបាច់ក្នុងក្របខណ្ឌនៃការអនុវត្តផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តមណ្ឌលគិរី (២០២១-២០៣៥) ដែលត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់ប្រធាន **គ.ជ.ផ.ម.**។

**មាត្រា៧.-**

**គ.ជ.ផ.ម.** មានលេខាធិការដ្ឋានមួយនៅក្រសួងទេសចរណ៍។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់ប្រធាន **គ.ជ.ផ.ម.**។

**មាត្រា៨.-**

**គ.ជ.ផ.ម.** មានសិទ្ធិប្រើប្រាស់ត្រារបស់គណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍នៅក្នុងកិច្ចដំណើរការការងារប្រចាំថ្ងៃរបស់ខ្លួន។

## ជំពូកទី៥

## ប្រភពធនធានរបស់គ.ជ.ផ.ម.

**មាត្រា៩.-**

ការចំណាយសម្រាប់កិច្ចដំណើរការ **គ.ជ.ផ.ម.** ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិក្នុងគម្រោងថវិការបស់ក្រសួងទេសចរណ៍។

**គ.ជ.ផ.ម.** មានសិទ្ធិទទួលនិងចាត់ចែងប្រើប្រាស់នូវធនធាននិងមូលនិធិដែលបានមកពីប្រភពស្របច្បាប់ផ្សេងៗទៀតតាមនីតិវិធីច្បាប់ជាធរមាន សម្រាប់កិច្ចដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**មាត្រា១០ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា១១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ